**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## បែបបទសម្រាប់អនុវត្តចំពោះការអនុញ្ញាតឲ្យជនបរទេសមិនមែន អន្តោប្រវេសន្ត ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០៥/នស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

- បានឃើញអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងជនបរទេសមិនមែនអន្តោប្រវេសន្តនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់បែបបទចូល ចេញ និងស្នាក់អាស្រ័យចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## បែបបទសម្រាប់ការចូល ចេញព្រះរាជាណាចក្រកម្ពុជា

**មាត្រា៤.-**

ជនបរទេសមិនមែនអន្តោប្រវេសន្តដែលមានបំណងចូលមកព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យស្នើសុំទិដ្ឋាការចូលតាមរយៈទីកន្លែងដូចខាងក្រោម៖

-ស្ថានបេសកកម្មការទូត ឬស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលកិត្តិយសនៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស

-ច្រកទ្វារអន្តរជាតិ

-គេហទំព័រទិដ្ឋាការអេឡិចត្រូនិចសម្រាប់ប្រភេទទេសចរណ៍។

**មាត្រា៥.-**

ចំពោះប្រទេសដែលមានចុះកិច្ចព្រមព្រៀងលើកលែងទិដ្ឋាការជាមួយព្រះរាជាណាចក្រកម្ពុជា អ្នកកាន់

លិខិតឆ្លងដែនការទូត ផ្លូវការ ពិសេស និងធម្មតា ត្រូវបានកំណត់ការស្នាក់នៅទៅតាមកិច្ចព្រមព្រៀងនោះ។ ក្នុងករណីជនបរទេសកាន់លិខិតឆ្លងដែនគ្រប់ប្រភេទ មានបំណងស្នាក់នៅលើសពីរយៈពេលកំណត់ក្នុងកិច្ចព្រមព្រៀង តម្រូវឲ្យស្នើសុំទិដ្ឋាការតាមប្រភេទដូចមានចែងក្នុងមាត្រា៩ នៃអនុក្រឹត្យនេះ។

**មាត្រា៦.-**

ការស្នើសុំទិដ្ឋាការចូលរបស់ជនបរទេសមិនមែនអន្តោប្រវេសន្ត នៅស្ថានបេសកកម្មការទូត ឬស្ថានអគ្គកុងស៊ុល និងស្ថានកុងស៊ុលកិត្តិយសនៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស និងនៅច្រកទ្វារអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជាត្រូវបំពេញបែបបទដូចតទៅ៖

១-បំពេញពាក្យសុំទិដ្ឋាការចូល។

២-បង្ហាញលិខិតឆ្លងដែន ឬឯកសារធ្វើដំណើរផ្សេងៗមានតម្លៃស្មើ ដែលត្រូវមានសុពលភាពយ៉ាងតិច៦(ប្រាំមួយ)ខែ។

៣-ផ្តល់រូបថតទំហំ ៤ x ៦ ចំនួន១(មួយ)សន្លឹក។

៤-ជនបរទេសដែលប្រើប្រាស់លិខិតឆ្លងដែនធ្វើដំណើររួមជាមួយឪពុកម្តាយ ឬអ្នកអាណាព្យាបាល អាចបំពេញបែបបទនិងចុះឈ្មោះរួមជាមួយឪពុកម្តាយ ឬអ្នកអាណាព្យាបាលរបស់ខ្លួនប៉ុន្តែត្រូវបង់អាករ ដូចជនបរទេសដែលប្រើប្រាស់លិខិតឆ្លងដែនដាច់ដោយឡែកដែរ។

៥-បង់អាករតាមការកំណត់ដូចមានចែងក្នុងមាត្រា១៦ នៃអនុក្រឹត្យនេះ។ អាករទិដ្ឋាការនេះមិនត្រូវបានសងវិញទេ ទោះក្នុងករណីនៃការស្នើសុំទិដ្ឋាការនោះ ត្រូវបានបដិសេធក៏ដោយ។

ចំពោះការស្នើសុំទិដ្ឋាការប្រភេទ K សាមីជនត្រូវភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធបញ្ជាក់ថាពិតជាមានសញ្ជាតិខ្មែរពីកំណើត។

**មាត្រា៧.-**

ការស្នើសុំទិដ្ឋាការចូលរបស់ជនបរទេសមិនមែនអន្តោប្រវេសន្ត តាមរយៈគេហទំព័រទិដ្ឋាការអេឡិចត្រូនិចសម្រាប់ប្រភេទទេសចរណ៍ ត្រូវបំពេញបែបបទដូចតទៅ៖

១-ចូលទៅគេហទំព័រទិដ្ឋាការអេឡិចត្រូនិច ដែលកំណត់ដោយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

២-បំពេញពាក្យស្នើសុំទិដ្ឋាការចូល និងបញ្ចូលរូបថត។

៣-លិខិតឆ្លងដែនត្រូវមានសុពលភាពយ៉ាងតិច៦(ប្រាំមួយ)ខែ។

៤-ជនបរទេសដែលប្រើប្រាស់លិខិតឆ្លងដែនធ្វើដំណើររួមជាមួយឪពុកម្តាយ ឬអ្នកអាណាព្យាបាល អាចបំពេញបែបបទនិងចុះឈ្មោះរួមជាមួយឪពុកម្តាយ ឬអ្នកអាណាព្យាបាលរបស់ខ្លួន ប៉ុន្តែត្រូវបង់អាករដូចជនបរទេសដែលប្រើប្រាស់លិខិតឆ្លងដែនដាច់ដោយឡែកដែរ។

៥-បង់អាករតាមបណ្ណតណទាន។

អាករទិដ្ឋាការនេះត្រូវបានបង្វិលសងវិញក្នុងករណីអាជ្ញាធរអន្តោប្រវេសន៍នៅច្រកទ្វារអន្តរជាតិ ពុំអនុញ្ញាតឲ្យចូលដោយមូលហេតុប្រព័ន្ធបច្ចេកទេសនៃទិដ្ឋាការអេឡិចត្រូនិច ឬព័ត៌មានមិនគ្រប់គ្រាន់។

**មាត្រា៨.–**

ការស្នើសុំទិដ្ឋាការចេញរបស់ជនបរទេសមិនមែនអន្តោប្រវេសន្ត ត្រូវបំពេញបែបបទដូចតទៅ៖

១-បំពេញពាក្យសុំទិដ្ឋាការចេញ។

២-បង្ហាញលិខិតឆ្លងដែន ឬឯកសារណាមួយដែលមានតម្លៃស្មើ។

៣-ផ្តល់រូបថតទំហំ ៤ x ៦ ចំនួន២ (ពីរ) សន្លឹក។

៤-ភ្ជាប់មកជាមួយនូវ៖

-ពាក្យប្តឹងនៃការបាត់បង់ឬខូចលិខិតឆ្លងដែន ដែលទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច។ ប្រទេសដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែពុំមាននិវេសនដ្ឋាននៅព្រះរាជាណាចក្រកម្ពុជាអាចធ្វើលិខិតឆ្លងដែនថ្មីឬឯកសារធ្វើដំណើរដែលមានតម្លៃស្មើឲ្យពលរដ្ឋរបស់ខ្លួនប្រើប្រាស់សម្រាប់ស្នើសុំទិដ្ឋាការចេញ មកក្រសួងមហាផ្ទៃ ឬតាមរយៈផ្លូវការទូត

-លិខិតដោះលែងពីពន្ធនាគារ តាមសេចក្តីសម្រេចរបស់តុលាការ

-សំបុត្របញ្ជាក់កំណើត ឬឯកសារដែលមានតម្លៃស្មើចំពោះកូនដែលកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬឯកសារពាក់ព័ន្ធផ្សេងៗទៀតក្នុងករណីចាំបាច់។

៥-បង់អាករតាមការកំណត់ដូចមានចែងក្នុងមាត្រា១៦នៃអនុក្រឹត្យនេះ។ អាករទិដ្ឋាការនេះមិនត្រូវបានសងវិញទេ ក្នុងករណីទិដ្ឋាការនោះផុតសុពលភាព។

## ជំពូកទី៣

## ប្រភេទ សុពលភាព រយៈពេលស្នាក់នៅ និងអាករនៃទិដ្ឋាការ

**មាត្រា៩.–**

ប្រភេទទិដ្ឋាការចូល ត្រូវបានកំណត់ដូចខាងក្រោម៖

១-**ទិដ្ឋាការការទូត** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ A។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តដែលកាន់លិខិតឆ្លងដែនការទូតនិងក្រុមគ្រួសារ។

២-**ទិដ្ឋាការផ្លូវការ** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ B។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលកាន់លិខិតឆ្លងដែនផ្លូវការមកបំពេញបេសកកម្មក្នុងក្របខណ្ឌរដ្ឋ ឬក្នុងក្របខណ្ឌអង្គការអន្តរជាតិនានាដែលបានចុះអនុស្សរណៈជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

៣-**ទិដ្ឋាការចៅរីតាព** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ C។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តនិងក្រុមគ្រួសារ ដែលក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ឬក្រសួងនានាចាត់ទុកជាកិច្ចសហប្រតិបត្តិការ ឬការសម្តែងការគួរសម។

៤-**ទិដ្ឋាការឆ្លងកាត់** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ D។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តដែលជាអ្នកធ្វើដំណើរឆ្លងកាត់ អ្នកបើកបរ បុគ្គលិក និយោជិត និងកម្មករលើយានយន្ត រថភ្លើង នាវា ឬយន្តហោះ។

៥-**ទិដ្ឋាការធម្មតា** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ E។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តដែលមិនស្ថិតក្នុងប្រភេទទិដ្ឋាការណាមួយ សម្រាប់ចូល ចេញ តែមួយដង។

៦-**ទិដ្ឋាការធម្មតារយៈពេលវែង** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ E1 E2 និង E3។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះពាណិជ្ជករដែលមានបំណងចូល ចេញច្រើនដង តាមការកំណត់ជាគោលការណ៍របស់រាជរដ្ឋាភិបាល ក្នុងគោលដៅលើកតម្កើងសក្តានុពលសេដ្ឋកិច្ច និងបច្ចេកវិទ្យា។

៧-**ទិដ្ឋាការពិសេស** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ K។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះជនដែលមានសញ្ជាតិខ្មែរពីកំណើត ហើយកាន់លិខិតឆ្លងដែន ឬឯកសារធ្វើដំណើរបរទេស។

៨-**ទិដ្ឋាការអេកមិក** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ KHM។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះទេសចរដែលមានបំណងធ្វើដំណើរចូលទៅក្នុងបណ្តាប្រទេសក្នុងតំបន់យុទ្ធសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ចអាយេយ៉ាវឌី-ចៅប្រាយ៉ា-មេគង្គ ACMECS។

៩-**ទិដ្ឋាការទេសចរណ៍** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ T។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តដែលជាទេសចរ សម្រាប់ចូល ចេញ តែមួយដង។

១០-**ទិដ្ឋាការទេសចរណ៍រយៈពេលវែង** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ T1 T2 និងT3។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះទេសចរដែលមានបំណងចូល ចេញច្រើនដង តាមការកំណត់ជាគោលការណ៍របស់រាជរដ្ឋាភិបាលក្នុងគោលដៅលើកតម្កើងសក្តានុពលទេសចរណ៍និងវប្បធម៌។

**មាត្រា១០.—**

ប្រភេទទិដ្ឋាការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្ន ត្រូវបានកំណត់ដូចតទៅ៖

១-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលទទួលបានទិដ្ឋាការ A កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $A_{EX}$។

២-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលទទួលបានទិដ្ឋាការ B កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $B_{EX}$។

៣-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលទទួលបានទិដ្ឋាការ C កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $C_{EX}$។

៤-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តជានិយោជិត ពាណិជ្ជករ បុគ្គលិក ពលករ និងអ្នកប្រកបរបរផ្សេងៗដែលទទួលបានទិដ្ឋាការ E កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $E_B$។

៥-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តទូទៅ ដែលទទួលបានទិដ្ឋាការ E កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $E_G$។

៦-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តជាអ្នកស្វែងយល់អាជីវកម្មដែលទទួលបានទិដ្ឋាការ E កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $E_P$។

៧-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តជានិវត្តជន ដែលទទួលបានទិដ្ឋាការ E កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $E_R$។

៨-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តជាសិស្សនិស្សិតដែលទទួលបានទិដ្ឋាការ E កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $E_S$។

៩-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តជាអ្នកបច្ចេកទេសជំនាញដែលទទួលបានទិដ្ឋាការ E កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $E_T$។

១០-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តជាពាណិជ្ជករ ដែលទទួលបានទិដ្ឋាការ E1 E2 និង E3 កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $E1_{EX}$ $E2_{EX}$ និង $E3_{EX}$។

១១-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តជាទេសចរ ដែលទទួលបានទិដ្ឋាការអេឡិចត្រូនិចសម្រាប់ប្រភេទទេសចរណ៍ និង KHM កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $T_{EX}$។

១២-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តជាទេសចរ ដែលទទួលបានទិដ្ឋាការ T កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $T_{EX}$។

១៣-ទិដ្ឋាការបន្តរយៈពេលស្នាក់នៅសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តជាទេសចរ ដែលទទួលបានទិដ្ឋាការ T1 T2 និង T3 កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $T1_{EX}$ $T2_{EX}$ និង $T3_{EX}$។

**មាត្រា១១.-**

**ទិដ្ឋាការចេញ** កំណត់សម្គាល់ដោយអក្សរឡាតាំងធំ $E_X$។ ទិដ្ឋាការនេះសម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តដែលទើបទទួលបានលិខិតឆ្លងដែនថ្មី ឬឯកសារធ្វើដំណើរដែលមានតម្លៃស្មើផ្តល់ដោយស្ថានទូត ឬស្ថានកុងស៊ុលបរទេស ហើយសាមីខ្លួនមានបំណងចាកចេញពីព្រះរាជាណាចក្រកម្ពុជា។

ទិដ្ឋាការនេះក៏សម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលតម្រូវឲ្យចាកចេញផុតពីព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១២.-**

គំរូនិងលក្ខណៈសម្គាល់នៃប្រភេទទិដ្ឋាការនីមួយៗត្រូវសម្រេចដាក់ឲ្យអនុវត្តដោយប្រកាសអន្តរក្រសួង រវាង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៣.-**

ទិដ្ឋាការត្រូវបានកំណត់សុពលភាពគិតចាប់ពីថ្ងៃចេញទិដ្ឋាការនោះតាមប្រភេទដូចខាងក្រោម៖

| | |
|---|---|
| -ទិដ្ឋាការប្រភេទ A | មានសុពលភាពមិនលើស ៣(បី)ខែ |
| -ទិដ្ឋាការប្រភេទ B | មានសុពលភាពមិនលើស ៣(បី)ខែ |
| -ទិដ្ឋាការប្រភេទ C | មានសុពលភាពមិនលើស ៣(បី)ខែ |
| -ទិដ្ឋាការប្រភេទ D | មានសុពលភាពមិនលើស ៧(ប្រាំពីរ)ថ្ងៃ |
| -ទិដ្ឋាការប្រភេទ E | មានសុពលភាពមិនលើស ៣(បី)ខែ |
| -ទិដ្ឋាការប្រភេទ E1 | មានសុពលភាព ១(មួយ)ឆ្នាំ |
| -ទិដ្ឋាការប្រភេទ E2 | មានសុពលភាព ២(ពីរ)ឆ្នាំ |
| -ទិដ្ឋាការប្រភេទ E3 | មានសុពលភាព ៣(បី)ឆ្នាំ |
| -ទិដ្ឋាការប្រភេទ Ex | មានសុពលភាព ៧(ប្រាំពីរ)ថ្ងៃ |
| -ទិដ្ឋាការប្រភេទ K | មានសុពលភាពត្រឹមថ្ងៃផុតកំណត់នៃលិខិតឆ្លងដែន |
| -ទិដ្ឋាការប្រភេទ KHM | មានសុពលភាពមិនលើស ៣(បី)ខែ |
| -ទិដ្ឋាការប្រភេទ T | មានសុពលភាពមិនលើស ៣(បី)ខែ |
| -ទិដ្ឋាការប្រភេទ T1 | មានសុពលភាព ១(មួយ)ឆ្នាំ |
| -ទិដ្ឋាការប្រភេទ T2 | មានសុពលភាព ២(ពីរ)ឆ្នាំ |
| -ទិដ្ឋាការប្រភេទ T3 | មានសុពលភាព ៣(បី)ឆ្នាំ |

ស្ថានបេសកកម្មការទូត ឬស្ថានអគ្គកុងស៊ុលកម្ពុជានៅក្រៅប្រទេស អាចផ្តល់ទិដ្ឋាការការទូតប្រភេទ A មានសុពលភាព១(មួយ)ឆ្នាំ ចូល ចេញច្រើនដង ដល់អ្នកការទូតបរទេសប្រចាំនៅកម្ពុជាដែលពុំមាននិវេសនដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងករណីដែលទិដ្ឋាការផុតសុពលភាព ជនបរទេសដែលទទួលបានទិដ្ឋាការនេះ និងមិនទាន់បានចូល ឬចេញពីព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យសុំទិដ្ឋាការជាថ្មី។

**មាត្រា១៤.-**

ជនបរទេសដែលទទួលបានទិដ្ឋាការចូលព្រះរាជាណាចក្រកម្ពុជា អាចស្នាក់នៅតាមរយៈពេលដូចខាងក្រោម៖

| | |
|---|---|
| -ទិដ្ឋាការប្រភេទ A | រយៈពេល ៣(បី)ខែ |
| -ទិដ្ឋាការប្រភេទ B | រយៈពេល ៣(បី)ខែ |
| -ទិដ្ឋាការប្រភេទ C | រយៈពេល ៣(បី)ខែ |
| -ទិដ្ឋាការប្រភេទ D | រយៈពេល ៥(ប្រាំ)ថ្ងៃ |
| -ទិដ្ឋាការប្រភេទ E | រយៈពេល ១(មួយ)ខែ |
| -ទិដ្ឋាការប្រភេទ E1 | រយៈពេល ១(មួយ)ខែ |

| | |
|---|---|
| -ទិដ្ឋាការប្រភេទ E2 | រយៈពេល ១(មួយ)ខែ |
| -ទិដ្ឋាការប្រភេទ E3 | រយៈពេល ១(មួយ)ខែ |
| -ទិដ្ឋាការប្រភេទ K | រយៈពេលត្រឹមថ្ងៃផុតកំណត់នៃលិខិតឆ្លងដែន |
| -ទិដ្ឋាការប្រភេទ KHM | រយៈពេល ១(មួយ)ខែ |
| -ទិដ្ឋាការប្រភេទ T | រយៈពេល ១(មួយ)ខែ |
| -ទិដ្ឋាការប្រភេទ T1 | រយៈពេល ១(មួយ)ខែ |
| -ទិដ្ឋាការប្រភេទ T2 | រយៈពេល ១(មួយ)ខែ |
| -ទិដ្ឋាការប្រភេទ T3 | រយៈពេល ១(មួយ)ខែ |

ការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្នត្រូវអនុវត្តតាមការកំណត់ដូចមានចែងក្នុងមាត្រា១៩នៃអនុក្រឹត្យនេះ។

**មាត្រា១៥.–**

គោលបំណងនៃការស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជារបស់ជនបរទេសមិនមែនអន្តោប្រវេសន្តត្រូវស្របតាមប្រភេទនៃទិដ្ឋាការដែលផ្តល់ឲ្យ ឬកិច្ចព្រមព្រៀងស្តីពីការលើកលែងទិដ្ឋាការជាមួយព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៦.–**

អាករទិដ្ឋាការចូល ចេញ បែបបទ និងនីតិវិធីនៃការប្រមូលអាករនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីទទួលបានការយល់ព្រមពីប្រមុខរាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការផ្តល់ ការបដិសេធទិដ្ឋាការចូល ចេញ
## និងបែបបទ រយៈពេល អាករ នៃការបន្តពេលស្នាក់នៅបណ្តោះអាសន្ន

**មាត្រា១៧.–**

ក-ស្ថានបេសកកម្មការទូត ឬស្ថានអគ្គកុងស៊ុល និងស្ថានកុងស៊ុលកិត្តិយសនៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេសមានសមត្ថកិច្ចផ្តល់ ឬបដិសេធទិដ្ឋាការគ្រប់ប្រភេទលើកលែងទិដ្ឋាការអេឡិចត្រូនិចសម្រាប់ប្រភេទទេសចរណ៍។

ខ-ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិមានសមត្ថកិច្ចៈ

-ផ្តល់ ឬបដិសេធទិដ្ឋាការអេឡិចត្រូនិចសម្រាប់ប្រភេទទេសចរណ៍

-បន្តការស្នាក់នៅបណ្តោះអាសន្ន និងកំណត់ការចូល ចេញមួយ ឬច្រើនដង ចំពោះទិដ្ឋាការប្រភេទ A B និង C។

គ-ក្រសួងមហាផ្ទៃមានសមត្ថកិច្ចៈ

-ផ្តល់ឬបដិសេធទិដ្ឋាការគ្រប់ប្រភេទនៅតាមបណ្តាច្រកទ្វារអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា លើកលែងទិដ្ឋាការអេឡិចត្រូនិចសម្រាប់ប្រភេទទេសចរណ៍ និង KHM

-បន្តការស្នាក់នៅបណ្តោះអាសន្ននិងកំណត់ការចូល ចេញមួយ ឬច្រើនដង ចំពោះទិដ្ឋាការគ្រប់ប្រភេទ លើកលែងប្រភេទ A B និង C។

**មាត្រា១៨.-**

ការចូល ចេញមួយ ឬច្រើនដងសម្រាប់ទិដ្ឋាការគ្រប់ប្រភេទត្រូវបានកំណត់ដូចតទៅៈ

-ទិដ្ឋាការប្រភេទ A ចូល ចេញ ច្រើនដង

-ទិដ្ឋាការប្រភេទ B ចូល ចេញ មួយដង

-ទិដ្ឋាការប្រភេទ C ចូល ចេញ មួយដង

-ទិដ្ឋាការប្រភេទ D ចូល ចេញ មួយដង

-ទិដ្ឋាការប្រភេទ E ចូល ចេញ មួយដង

-ទិដ្ឋាការប្រភេទ E1 ចូល ចេញ ច្រើនដង

-ទិដ្ឋាការប្រភេទ E2 ចូល ចេញ ច្រើនដង

-ទិដ្ឋាការប្រភេទ E3 ចូល ចេញ ច្រើនដង

-ទិដ្ឋាការប្រភេទ Ex ចេញមួយដង

-ទិដ្ឋាការប្រភេទ K ចូល ចេញ ច្រើនដង

-ទិដ្ឋាការប្រភេទ KHM ចូល ចេញ មួយដង

-ទិដ្ឋាការប្រភេទ T ចូល ចេញ មួយដង

-ទិដ្ឋាការប្រភេទ T1 ចូល ចេញ ច្រើនដង

-ទិដ្ឋាការប្រភេទ T2 ចូល ចេញ ច្រើនដង

-ទិដ្ឋាការប្រភេទ T3 ចូល ចេញ ច្រើនដង។

**មាត្រា១៩.-**

ការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្នត្រូវបានកំណត់ដូចតទៅៈ

-ទិដ្ឋាការប្រភេទ $A_{EX}$ អាចបន្តរយៈពេលបានពី១(មួយ)ខែ រហូតដល់ចប់បេសកកម្ម

-ទិដ្ឋាការប្រភេទ $B_{EX}$ អាចបន្តរយៈពេលបានពី១(មួយ)ខែ ដល់១២(ដប់ពីរ)ខែ ម្តង រហូតដល់ចប់បេសកកម្ម

-ទិដ្ឋាការប្រភេទ $C_{EX}$ អាចបន្តរយៈពេលបានពី១(មួយ)ខែ ដល់១២(ដប់ពីរ)ខែ ម្តង

-ទិដ្ឋាការប្រភេទ D មិនអាចបន្តរយៈពេលបានទេ លើកលែងតែក្នុងករណីជាក់ស្តែងនិងចាំបាច់បំផុត សាមីខ្លួនអាចស្នើសុំបន្តរយៈពេលស្នាក់នៅដូចទិដ្ឋាការប្រភេទ $T_{EX}$

| | |
|---|---|
| -ទិដ្ឋាការប្រភេទ $E_B$ | អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ ឬ៦(ប្រាំមួយ)ខែ ឬ ១២(ដប់ពីរ)ខែ |
| -ទិដ្ឋាការប្រភេទ $E_G$ | អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ ឬ៦(ប្រាំមួយ)ខែ តែម្តងគត់ |
| -ទិដ្ឋាការប្រភេទ $E_P$ | អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ តែម្តងគត់ |
| -ទិដ្ឋាការប្រភេទ $E_R$ | អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ ឬ៦(ប្រាំមួយ)ខែ ឬ ១២(ដប់ពីរ)ខែ |
| -ទិដ្ឋាការប្រភេទ $E_S$ | អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ ឬ៦(ប្រាំមួយ)ខែ ឬ ១២(ដប់ពីរ)ខែ |
| -ទិដ្ឋាការប្រភេទ $E_T$ | អាចបន្តរយៈពេលបាន២៤(ម្ភៃបួន)ខែ បន្ទាប់មកអាចបន្តបាន១២(ដប់ពីរ)ខែ បីដងទៀត ហើយតម្រូវឲ្យចាកចេញពីប្រទេស |
| -ទិដ្ឋាការប្រភេទ $E1_{EX}$ | អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ ឬ៦(ប្រាំមួយ)ខែ ឬ ១២(ដប់ពីរ)ខែ |
| -ទិដ្ឋាការប្រភេទ $E2_{EX}$ | អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ ឬ៦(ប្រាំមួយ)ខែ ឬ ១២(ដប់ពីរ)ខែ |
| -ទិដ្ឋាការប្រភេទ $E3_{EX}$ | អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ ឬ៦(ប្រាំមួយ)ខែ ឬ ១២(ដប់ពីរ)ខែ |
| -ទិដ្ឋាការប្រភេទ $T_{EX}$ | អាចបន្តរយៈពេលបាន១(មួយ)ខែ តែម្តងគត់ |
| -ទិដ្ឋាការប្រភេទ $T1_{EX}$ | អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ តែម្តងគត់ |
| -ទិដ្ឋាការប្រភេទ $T2_{EX}$ | អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ តែម្តងគត់ |
| -ទិដ្ឋាការប្រភេទ $T3_{EX}$ | អាចបន្តរយៈពេលបាន១(មួយ)ខែ ឬ៣(បី)ខែ តែម្តងគត់ |

ចំពោះការស្នើសុំបន្តរយៈពេលស្នាក់នៅទិដ្ឋាការគ្រប់ប្រភេទ លើកលែង A B និង C សាមីជនត្រូវមកបង្ហាញខ្លួនដើម្បីបំពេញបែបបទដោយផ្ទាល់នៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ។

**មាត្រា២០.-**

បែបបទស្នើសុំការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្ននៃទិដ្ឋាការគ្រប់ប្រភេទមានដូចតទៅ៖

១-បំពេញពាក្យសុំបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្ន។

២-ភ្ជាប់មកជាមួយនូវលិខិតឆ្លងដែនដែលមានសុពលភាពយ៉ាងតិច៦(ប្រាំមួយ)ខែ លើសពីរយៈពេលស្នើសុំបន្តស្នាក់នៅបណ្តោះអាសន្ន។

៣-រូបថតទំហំ ៤ x ៦ ចំនួន១(មួយ)សន្លឹក។

៤-ត្រូវបង់ ឬលើកលែងអាករតាមការកំណត់ក្នុងមាត្រា២២ នៃអនុក្រឹត្យនេះ។

៥-ចំពោះការស្នើសុំបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្ន ដែលទទួលបានពីទិដ្ឋាការធម្មតា E សាមីជនត្រូវភ្ជាប់មកជាមួយនូវ៖

ក-ទិដ្ឋាការប្រភេទ $E_B$

-លិខិតប្រកបអាជីវកម្ម និងបណ្ណប៉ាតង់ ឬ

-កិច្ចសន្យាការងារ ឬ

-ឯកសារពាក់ព័ន្ធបញ្ជាក់ថាពិតជាមានការចាំបាច់ក្នុងការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្នមែន

-ឯកសារបញ្ជាក់ថាពិតជាមានជាប់ពាក់ព័ន្ធជាសហព័ទ្ធ ឬកូន។

ខ-ទិដ្ឋាការប្រភេទ $E_G$

-ឯកសារពាក់ព័ន្ធបញ្ជាក់ពីគោលបំណងរបស់ខ្លួន។

គ-ទិដ្ឋាការប្រភេទ $E_P$

-គម្រោង ឬ

-ឯកសារពាក់ព័ន្ធបញ្ជាក់ពីគោលបំណងរបស់ខ្លួន។

ឃ-ទិដ្ឋាការប្រភេទ $E_R$

-ឯកសារ ឬលិខិតបញ្ជាក់ពីការចូលនិវត្តន៍របស់ខ្លួន

-ឯកសារបង្ហាញពីប្រាក់សោធននិវត្តន៍ពីធនាគារ ឬឯកសារពាក់ព័ន្ធផ្សេងៗ។

ង-ទិដ្ឋាការប្រភេទ $E_S$

-លិខិតបញ្ជាក់ពីគ្រឹះស្ថានសិក្សា ទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យអប់រំ

-ការធានាពីឪពុក ម្តាយ ឬអ្នកអាណាព្យាបាល ដែលបញ្ជាក់ថាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទំនុកបម្រុងថ្លៃសិក្សា ឬឯកសារពាក់ព័ន្ធផ្សេងៗ។

ច-ទិដ្ឋាការប្រភេទ $E_T$

-អាជ្ញាបណ្ណក្រុមហ៊ុន សហគ្រាស ឬអង្គភាពដែលសាមីជនកំពុងបម្រើការងារ

-កិច្ចសន្យាការងារ

-ឯកសារបញ្ជាក់ថាពិតជាមានជាប់ពាក់ព័ន្ធជាប្តី ប្រពន្ធ ឬកូន ចំពោះសហព័ទ្ធ និងកូនរបស់សាមីខ្លួន។

**មាត្រា២១.-**

ទោះក្នុងករណីលិខិតឆ្លងដែនត្រូវបានបាត់ ឬខូចទ្រង់ទ្រាយដើមក៏ដោយ ទិដ្ឋាការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្ននៅតែមានសុពលភាពដដែល។

សាមីជនត្រូវស្នើសុំមកក្រសួងមហាផ្ទៃដើម្បីផ្ទេរទិដ្ឋាការបន្តរយៈពេលស្នាក់នៅដែលនៅមានសុពលភាពនោះមកលើលិខិតឆ្លងដែនថ្មីរបស់ខ្លួនដោយមិនបង់អាករ។

**មាត្រា២២.-**

អាករនៃការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្ន របៀបបទ និងនីតិវិធីនៃការប្រមូលអាករនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីទទួលបានការយល់ព្រមពីប្រមុខរាជរដ្ឋាភិបាល។

អាករគ្រប់ប្រភេទខាងលើត្រូវបង់ចូលថវិកាជាតិ។

## ជំពូកទី៥
## ការហាមឃាត់ការចូល ចេញ និងការស្នាក់នៅបណ្តោះអាសន្ន

**មាត្រា២៣.-**

ត្រូវហាមឃាត់ការចូល ចេញ និងការស្នាក់នៅបណ្តោះអាសន្នក្នុងព្រះរាជាណាចក្រកម្ពុជាចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ក្នុងករណីដូចខាងក្រោម៖

ក- ការហាមឃាត់ការចូល

១-លិខិតឆ្លងដែន ឬឯកសារធ្វើដំណើរគ្មានតម្លៃ។

២-គ្មានទិដ្ឋាការចូល លើកលែងប្រទេសដែលមានកិច្ចព្រមព្រៀងជាមួយព្រះរាជាណាចក្រកម្ពុជា។

៣-វិកលចរិត។

៤-មានឈ្មោះក្នុងបញ្ជីហាមចូលដែលកំណត់ដោយក្រសួងមហាផ្ទៃ។

៥-មានផ្ទុកជម្ងឺឆ្លងធ្ងន់ធ្ងរដែលប្រកាសដោយរាជរដ្ឋាភិបាល។

៦-កំពុងជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

៧-ប្រវត្តិនៃការធ្វើដំណើរមិនច្បាស់លាស់។

៨-គោលបំណងនៃការធ្វើដំណើរមិនច្បាស់លាស់។

៩-ខ្វះលទ្ធភាពចិញ្ចឹមខ្លួន និងក្រុមគ្រួសារគ្មានជនណាផ្សេងធានាជួយដោះស្រាយ។

១០-ក្លែងបន្លំ កោស លុប សរសេរត្រួត ឬបន្ថែមទិន្នន័យនៅលើឯកសារធ្វើដំណើរ ឬឯកសារពាក់ព័ន្ធផ្សេងៗ។

១១-ធ្លាប់បានបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា។ ការអនុញ្ញាតផ្តល់ទិដ្ឋាការឲ្យចូលវិញត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

១២-បានលួចឡើងនាវា រថយន្ត រថភ្លើង ឬយន្តហោះចូលមកព្រះរាជាណាចក្រកម្ពុជា។

១៣-ក្រសួងមហាផ្ទៃមានហេតុផលគ្រប់គ្រាន់ជឿថានឹងប្រព្រឹត្តសកម្មភាពធ្វើឲ្យខូចផលប្រយោជន៍សណ្តាប់ធ្នាប់សាធារណៈ សីលធម៌សង្គម និងធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខជាតិ អន្តរជាតិ។

ក្នុងករណីអ្នកស្នើសុំទិដ្ឋាការចូល មានមូលហេតុក្នុងចំណុចណាមួយខាងលើ អាជ្ញាធរមានសមត្ថកិច្ចក្រសួងមហាផ្ទៃ ត្រូវបញ្ជូនសាមីជនឲ្យចាកចេញផុតពីព្រះរាជាណាចក្រកម្ពុជាទៅគោលដៅដើមវិញ។

ខ- ការហាមឃាត់ការចេញ

១-គ្មានទិដ្ឋាការចេញ ។

២-សាមីជនកំពុងស្ថិតក្នុងបណ្តឹងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី។

៣-គេចវេះពីទោសទណ្ឌ ឬការទទួលខុសត្រូវរបស់ខ្លួនចំពោះមុខច្បាប់។

៤-ជនដែលក្លែងបន្លំ កោស លុប សរសេរត្រួត ឬបន្ថែមទិន្នន័យនៅលើឯកសារធ្វើដំណើរ ឬឯកសារពាក់ព័ន្ធផ្សេងៗ។

៥-មិនបង់ប្រាក់ពិន័យអន្តរការណ៍លើការស្នាក់នៅហួសរយៈពេលកំណត់ លើកលែងមានការសម្រេចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

៦-ក្រសួងមហាផ្ទៃមានហេតុផលគ្រប់គ្រាន់ជឿថា ការចាកចេញពីព្រះរាជាណាចក្រកម្ពុជារបស់ជនបរទេសរូបនោះនឹងធ្វើឲ្យខូចផលប្រយោជន៍សាធារណៈ ឬប្រជាពលរដ្ឋខ្មែរ។

ក្នុងករណីអ្នកស្នើសុំទិដ្ឋាការចេញមានមូលហេតុក្នុងចំណុចណាមួយខាងលើ សាមីជនត្រូវដោះស្រាយចំពោះមុខច្បាប់ជាធរមាន។

គ- ការហាមឃាត់ការស្នាក់នៅបណ្តោះអាសន្ន

១-លិខិតឆ្លងដែន ឬឯកសារធ្វើដំណើរគ្មានតម្លៃ។

២-គ្មានទិដ្ឋាការចូល លើកលែងតែប្រទេសដែលមានកិច្ចព្រមព្រៀងជាមួយព្រះរាជាណាចក្រកម្ពុជា។

៣-វិកលចរិត។

៤-គ្មានបោះត្រាបញ្ជាក់ការចូលព្រះរាជាណាចក្រកម្ពុជា ពីមន្ត្រីអន្តោប្រវេសន៍កម្ពុជាប្រចាំនៅច្រកទ្វារអន្តរជាតិ ឬច្រកទ្វារទ្វេភាគីណាមួយ។

៥-ខ្វះលទ្ធភាពចិញ្ចឹមខ្លួន និងក្រុមគ្រួសារគ្មានជនណាផ្សេងធានាជួយដោះស្រាយ ។

៦-ក្លែងបន្លំ កោស លុប សរសេរត្រួត ឬបន្ថែមទិន្នន័យនៅលើឯកសារធ្វើដំណើរ ទិដ្ឋាការ បណ្ណស្នាក់នៅ សៀវភៅការងារ ឬឯកសារពាក់ព័ន្ធផ្សេងៗ។

៧-ក្រសួងមហាផ្ទៃពិនិត្យឃើញថា មានអាកប្បកិរិយាធ្វើឲ្យខូចផលប្រយោជន៍សណ្តាប់ធ្នាប់សាធារណៈ សីលធម៌សង្គម និងធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខជាតិ អន្តរជាតិ។

ក្នុងករណីអ្នកស្នើសុំទិដ្ឋាការបន្តរយៈពេលស្នាក់នៅ មានមូលហេតុក្នុងចំណុចណាមួយខាងលើ អាជ្ញាធរមានសមត្ថកិច្ចក្រសួងមហាផ្ទៃ ត្រូវបណ្តេញសាមីជនឲ្យចាកចេញផុតពីព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២៤._**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អាចលុបចោលឬមិនពន្យារទិដ្ឋាការ ឬមិនអនុញ្ញាតឲ្យស្នាក់នៅបណ្តោះអាសន្នចំពោះមូលហេតុណាមួយដូចខាងក្រោម៖

១-ជនដែលកាន់ទិដ្ឋាការអាចបង្កឲ្យមានគ្រោះថ្នាក់ដល់សន្តិសុខជាតិ។

២-ទិដ្ឋាការដែលបានមកដោយការក្លែងបន្លំ ឬកោសលុប។

៣-ជនដែលកាន់ទិដ្ឋាការបានរំលោភលើបទប្បញ្ញត្តិ ឬច្បាប់នានានៃព្រះរាជាណាចក្រកម្ពុជា។

៤-ជនដែលកាន់ទិដ្ឋាការត្រូវបានកាត់ទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**មាត្រា២៥.-**

ជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលស្នាក់នៅហួសរយៈពេលកំណត់ក្រោម៣០(សាមសិប)ថ្ងៃ ត្រូវបង្ខំឲ្យបង់ប្រាក់ពិន័យអន្តរការណ៍ ១០(ដប់)ដុល្លារអាម៉េរិកក្នុងមួយថ្ងៃ ដែលអនុវត្តដោយអគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ។

**មាត្រា២៦.-**

១-ជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលស្នាក់នៅហួសរយៈពេលកំណត់លើសពី៣០(សាមសិប) ថ្ងៃ ត្រូវបង្ខំឲ្យបង់ប្រាក់ពិន័យអន្តរការណ៍ដោយអនុលោមតាមមាត្រា២៥នៃអនុក្រឹត្យនេះ ហើយតម្រូវឲ្យចាកចេញផុតពីព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល០៧(ប្រាំពីរ)ថ្ងៃយ៉ាងយូរ។

២-ក្នុងករណីរឹងរូស ឬគេចវេះ មិនចាកចេញពីកម្ពុជាតាមការកំណត់ដូចមានចែងក្នុងចំណុចទី១ខាងលើនេះ សាមីជនត្រូវបង្ខំឲ្យបង់ប្រាក់ពិន័យអន្តរការណ៍ទ្វេដង ហើយត្រូវដំណើរការនីតិវិធី និងរៀបចំបែបបទបណ្តេញចេញតាមច្បាប់ស្តីពីអន្តោប្រវេសន៍។

**មាត្រា២៧.-**

១-ជនបរទេសមិនមែនអន្តោប្រវេសន្តដែលមានសកម្មភាពផ្ទាល់ខ្លួនបង្ហាញថាបានប្រើប្រាស់ទិដ្ឋាការខុសពីគោលបំណងដែលបានស្នើសុំ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ស្មើនឹង១០០(មួយរយ)ដុល្លារអាម៉េរិក ហើយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវបញ្ជាឲ្យចាកចេញផុតពីព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល០៧(ប្រាំពីរ) ថ្ងៃយ៉ាងយូរ។

២-ក្នុងករណីរឹងរូស ឬគេចវេះមិនចេញពីកម្ពុជា តាមការកំណត់ដូចមានចែងក្នុងចំណុចទី១ខាងលើនេះ សាមីជនត្រូវបង្ខំឲ្យបង់ប្រាក់ពិន័យអន្តរការណ៍ទ្វេដង ហើយត្រូវដំណើរការនីតិវិធី និងរៀបចំបែបបទបណ្តេញចេញតាមច្បាប់ស្តីពីអន្តោប្រវេសន៍។

**មាត្រា២៨.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានសិទ្ធិលើកលែងការពិន័យដូចមានចែងក្នុងមាត្រា២៥ មាត្រា២៦ និងមាត្រា២៧ នៃអនុក្រឹត្យនេះ។

**មាត្រា២៩.-**

ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឲ្យរលត់បណ្តឹងអាជ្ញា។

ក្នុងករណីមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ សំណុំរឿងនៃបទល្មើសត្រូវបញ្ជូនទៅតុលាការតាមនីតិវិធី លើកលែងការអនុវត្តមាត្រា២៨ ខាងលើនេះ។

ប្រាក់ពិន័យអន្តរការណ៍ត្រូវបង់ចូលថវិកាជាតិ។

បែបបទ និងនីតិវិធីនៃការបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា៣០.-**

អនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពី បែបបទសំរាប់អនុវត្តចំពោះការអនុញ្ញាតអោយជនបរទេសមិនមែនអន្តោប្រវេសន្ត ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៣១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីគោរពជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី សូមហត្ថលេខា**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ